**ក្រុមប្រឹក្សារដ្ឋមន្ត្រី**

អនុក្រឹត្យ/ ០១ អនក្រ 				០១ កុម្ភ: ១៩៩៣

# អនុក្រឹត្យ
# ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ
# នៃអគ្គនាយកដ្ឋានអាកាសចរស៊ីវិលកម្ពុជា
# ក្រុមប្រឹក្សារដ្ឋមន្ត្រី

- បានឃើញ រដ្ឋធម្មនុញ្ញនៃរដ្ឋកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃក្រុមប្រឹក្សារដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយក្រឹត្យលេខ ៥០ក្រ. ចុះថ្ងៃទី ០២ ខែឧសភា ឆ្នាំ ១៩៩២
- បានឃើញច្បាប់ស្តីពីការបង្កើតអគ្គនាយកដ្ឋានអាកាសចរស៊ីវិលកម្ពុជា ដែលប្រកាសអោយប្រើដោយក្រឹត្យលេខ ៩១ក្រ. ចុះថ្ងៃទី ២៧ ខែសីហា ឆ្នាំ១៩៩២
- បានឃើញ ក្រឹត្យច្បាប់លេខ ០៧ ក្រ.ច ចុះថ្ងៃទី ១៣ ខែកក្កដា ឆ្នាំ ១៩៨២ ស្តីពី សមត្ថកិច្ច និង នីតិវិធីនៃការធ្វើច្បាប់ និង បទបញ្ជា
- តាមសំណើ របស់អគ្គនាយក នៃអគ្គនាយកដ្ឋានអាកាសចរស៊ីវិលកម្ពុជា

## សំរេច

**មាត្រា ១.-**

អគ្គនាយកដ្ឋានអាកាសចរស៊ីវិលកម្ពុជា ជាស្ថាប័នចំណុះក្រុមប្រឹក្សារដ្ឋមន្ត្រី មានសមត្ថកិច្ចគ្រប់គ្រងក្នុងវិស័យអាកាសចរស៊ីវិល របស់រដ្ឋ ឯកជន ជាតិ និងអន្តរជាតិ ។

**មាត្រា ២.-**

អគ្គនាយកដ្ឋានអាកាសចរស៊ីវិលកម្ពុជា មានភារកិច្ច និងសិទ្ធិអំណាចដូចខាងក្រោម:

- គ្រប់គ្រងខាងផ្លូវរដ្ឋ អំពីវិស័យអាកាសចរស៊ីវិល
- គ្រប់គ្រងការធ្វើអាជីវកម្ម លើវិស័យអាកាសចរស៊ីវិល
- ទំនាក់ទំនងជាមួយអង្គការអាកាសចរ ក្រុមហ៊ុនអាកាសចរនានា ក្នុង និងក្រៅប្រទេស

- ចាត់តាំងបញ្ហាការហោះហើរ ត្រួតពិនិត្យគ្រប់គ្រងចរាចរដែនអាកាសរបស់ស៊ីវិល និងបច្ចេកទេសយន្តហោះរបស់អាកាសចរស៊ីវិល និងធានាទូរគមនាគមន៍អាកាសចរស៊ីវិល គ្រប់គ្រង និងបណ្តុះបណ្តាលមន្ត្រី បុគ្គលិកបច្ចេកទេសហិរញ្ញកិច្ច របស់អគ្គនាយកដ្ឋានអាកាសចរស៊ីវិលកម្ពុជា
- ទំនាក់ទំនងផ្ទាល់ជាមួយបណ្តាស្ថាប័នរដ្ឋ និងឯកជនតាមលក្ខការណ៍ ដែលរដ្ឋកំណត់
- សហការជាមួយក្រសួងមានសមត្ថកិច្ច ការពារសុវត្ថិភាព និងសន្តិសុខលើវិស័យអាកាសចរស៊ីវិល
- ត្រួតពិនិត្យការងារធានាសុវត្ថិភាព និងសន្តិសុខហោះហើររបស់យន្តហោះអាកាសចរស៊ីវិលគ្រប់ប្រភេទ
- ត្រួតពិនិត្យ និងផ្តល់វិញ្ញាបនប័ត្រអោយអាកាសយានិក និងអ្នកបច្ចេកទេស
- ធ្វើផែនការអភិវឌ្ឍន៍ និងនីតិកម្ម របស់អាកាសចរស៊ីវិល
- សំរុះសំរួលវិវាទផ្សេងៗ របស់អាកាសចរស៊ីវិល
- គ្រប់គ្រង និងចាត់ចែងប្រតិបត្តិការហោះហើរ របស់យន្តហោះរបស់អាកាសចរស៊ីវិលកម្ពុជាគ្រប់ប្រភេទ
- ត្រួតពិនិត្យ និងគ្រប់គ្រងបច្ចេកទេសសំណង់ របស់ចំណតយន្តហោះ
- ត្រួតពិនិត្យការងារដឹកជញ្ជូនតាមផ្លូវអាកាស
- ត្រួតពិនិត្យ និងគ្រប់គ្រងចំណតយន្តហោះស៊ីវិលទាំងអស់របស់រដ្ឋ
- ត្រួតពិនិត្យគុណភាពប្រេងឥន្ធនៈអាកាសចរស៊ីវិល
- ត្រួតពិនិត្យលិខិតស្នាមស្របច្បាប់ជាតិ និងអន្តរជាតិ អំពីវិស័យអាជីវកម្មបច្ចេកទេស និងសមត្ថភាព របស់អាកាសយានិក

**មាត្រា ៣.-**

រចនាសម្ព័ន្ធចាត់តាំង របស់អគ្គនាយកដ្ឋានអាកាសចរស៊ីវិលកម្ពុជា រួមមានៈ

- មន្ទីរ
- នាយកដ្ឋានប្រតិបត្តិការ
- នាយកដ្ឋានវិស្វកម្ម
- នាយកដ្ឋានដឹកជញ្ជូន
- នាយកដ្ឋានផ្គត់ផ្គង់ និងហិរញ្ញកិច្ច

**មាត្រា ៤.-**

ការរៀបចំអង្គការចាត់តាំងភារកិច្ច និងសិទ្ធិអំណាចជាក់ស្តែង របស់មន្ទីរនាយកដ្ឋានត្រូវកំណត់ដោយប្រកាសរបស់អគ្គនាយក នៃអគ្គនាយកដ្ឋានអាកាសចរស៊ីវិលកម្ពុជា ។

**មាត្រា ៥._**

អគ្គនាយកដ្ឋានអាកាសចរស៊ីវិលកម្ពុជា ដឹកនាំដោយអគ្គនាយកមួយរូប និងអគ្គនាយករង ជំនួយការ ។

**មាត្រា ៦._**

អនុក្រឹត្យលេខ ១១ GnRk.ចុះថ្ងៃទី ១២ ខែឧសភា ឆ្នាំ១៩៩២ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៧._**

រដ្ឋមន្ត្រីទទួលបន្ទុកខុទ្ទកាល័យក្រុមប្រឹក្សារដ្ឋមន្ត្រី អគ្គនាយកនៃអគ្គនាយកដ្ឋានអាកាសចរ ស៊ីវិលកម្ពុជា រដ្ឋមន្ត្រីក្រសួង ប្រធានស្ថាប័នពាក់ព័ន្ធ និងគណៈកម្មាធិការប្រជាជនខេត្ត-ក្រុង ត្រូវទទួលអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀង១ខ្លួន។

**មាត្រា ៨._**

អនុក្រឹត្យនេះ មានអានុភាពគតិយុត្តិ ចាប់តាំងពីថ្ងៃចុះហត្ថលេខានេះតទៅ ។

**ជ.ក្រុមប្រឹក្សារដ្ឋមន្ត្រី**

**អនុប្រធាន**

**ហត្ថលេខា និង ត្រា**

**សាយ ឈុំ**